# ពងនទភិ

Tome I



ន-ន
133

ARCHIVES NATIONALES
REGIE DU DEPOT LEGAL

# រឿងពលឯកខ្មែរ ១

ជារឿងបុរាណសាស្ត្រស្ទឹករត

អាចារ្យ

វ៉ង់-ឈឹន

នៅឃុំលេខ ៤ ក្រុងភ្នំពេញ

បានរៀបរៀង

ARCHIVES NATIONALES
COTE B.107.1258 82

ការផ្សាយរបស់

បណ្ណាគារ

សេង-លី

លេខ ៧ មហាវិថីមិសត៌ ក្រុងភ្នំពេញ

នៅមុខស្ថានីយ៍អយស្ម័យយាន

បោះពុម្ព ៣០០០ ច្បាប់

ព.ស ២៤៩៥, គ.ស. ១៩៥២

ទុកសិទ្ធិ

# អារម្ភកថា

រឿងពលឯកកុមារនេះ ដែលបានគង់វង់មកដល់សព្វថ្ងៃនេះ ដោយសារខ្ញុំបានមើលពីក្មេងនៅវត្តលាំងកំពូល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ, ខ្ញុំក៏បានចាំរឿងនោះរហូតមកដល់ឥឡូវនេះ កាលដែលខ្ញុំមើលគឺជាសាស្ត្រាស្លឹករឹតគេតែងជាបទកាកគតិនិងបទព្រហ្មគិតជាដើម, ឥឡូវនេះខ្ញុំយកមកតែងជាបទពាក្យប្រាំពីរ, កាលដែលខ្ញុំមើលអាយុ ១៣ ឆ្នាំ ព.ស.២៤៥៩ គ.ស. ១៩១៦ មកដល់អាយុ ៤៩ ឆ្នាំ ព.ស. ២៤៩៥ គ ស.១៩៥២ នេះ, ខ្ញុំក៏តែងរឿងពលឯកនេះឡើងធ្វើជាសៀវភៅពីរក្បាលគឺទី ១ និងទី ២ ព្រោះកុំឲ្យក្រាស់ពេក, ប្រាថ្នាទុកឲ្យខេមរជនបានអានបានមើលនិងបានក្រេបយករឿងនេះ ទុកជាទីមនោរម្យដល់លោកអានទាំងឡាយតទៅ ។

ខ្ញុំបាទតែងផ្ទៃរឿងនេះចប់ហើយ ក៏បានប្រគល់ឲ្យទៅថៅកែអ៊ាង ហួតផ្ទះលេខ....ខាងជើងផ្សារសួនថ្មី វិថីវីរវង និងថៅកែ សេង-លី មហាវិថីមិសត៍ក្ខុំពេញ ឲ្យបោះផ្សាយ គាត់ក៏មានសេចក្ដីរីករាយត្រេកអរណាស់ដោយបានរឿងបុរាណប្លែកល្អ, ខ្ញុំក៏មានចិត្តត្រេកអរថាមុខជានឹងបានរឿងពលឯកនេះ ចូលជ្រែកក្នុងសន្ដាននៃលោកអ្នកអានទាំងឡាយគ្រាន់ជាទីមនោរម្យពុំខាន ។

ទីបំផុតនេះ ខ្ញុំសូមអភ័យទោសអំពីសំណាក់នៃលោកអ្នកជាកងបណ្ឌិតទាំងឡាយ ក្រែងខ្ញុំតែងឃ្លៀងឃ្លាតសម្ផស្សពាក្យ សូមកុំនិន្ទ

ជាអ្វី បើឃើញខុសឃ្លៀងឃ្លាតត្រង់ណា សូមជម្រង់ត្រង់នោះឲ្យបាន
ផង ព្រោះខ្ញុំតែងប្រញាប់ប្រសាន់ពេក សៀវភៅភាគទី ១ នេះតែងតែ
មួយអាទិត្យប៉ុណ្ណោះឡើយ ។

# រឿងពលឯក

ខ្ញុំសូមថ្វាថ្លែងតែងជាកាព្យ- ប្រាំពីរពាក្យពបរៀងដល់ចប់
លោកអ្នកឯណាដែលប្រសប់- អានមើលដល់ចប់ដឹងសេចក្តី ។
រឿងនេះជារឿងបុរាណចាស់. មិនមែនជារឿងកើតថ្មីៗ
លោកអ្នកបេះអានទោះប្រុសស្រី ចាស់ក្តីក្មេងក្តីគិតផងចុះ ។
ដំណាលកាលរឿងចៅពលឯក ក្រីក្រពន់ពេកលំបាកស្មោះ
មាតាបិតាទល់ទាំងអស់ ទាំងទ្រព្យរបស់ក៏គ្មានអ្វី ។
នៅផ្ទះមួយតូចក្នុងព្រៃស្ងាត់ ឮតែសូរសត្វទាវទោចរ
ទីទុយមៀមមុំយំសព្វថ្ងៃ តែពីរនាក់ប្តីនឹងប្រពន្ធ ។
លន្ធលុះវេលាព្រឹកមួយ ដេកលក់ជាមួយស្វាមីលង់
សុបិននិមិត្តស្រស់ស្រីតន់ ឃើញតាចាស់កាន់កែវល្អក្រៃ ។
ដើរចូលជិតមកនាងវរលក្ខណ៍ យកកែវមកដាក់លើបាតដៃ
ដូចផ្លែពលឯកល្អពេកក្រៃ ដាក់ទៅលើដៃថយចេញទៅ ។
លុះនាងភ្ញាភ្ញាក់ឡើងកាលណា ជីតាដាស់ប្តីនាងស្រីពៅ
ថាអ្នកស្វាមីក្រោកឡើងភ្លូវ កុំនៅសម្រាន្តឲ្យយូរពេក ។
ជួយគាត់សប្តិខ្ញុំប្លែកឥម៉្លេះ សប្តិនេះហៅពេញជាចម្លែក
តាចាស់កាន់កែវក្រហមប្លែក ដូចផ្លែពលឯកដាក់លើដៃ ។
ស្រាប់តែខ្ញុំភ្ញាក់រកពុំឃើញ ស្តាយហើយសែនស្តាយឥតឧបម័យ

សប្តិនេះដូចម្តេចណាប្រុសថ្លៃ អ្នកជួយលកលៃគាត់បន្តិច ៗ
ប្អូនអើយសប្តិនេះល្អណាស់ណា បូរាណចាស់លោកប្រាប់
មុខជាបានកូនប្រុសសម្រេច បណ្តូលបណ្តាច់មានបុណ្យផង ៗ
លង់លុះយូរជាអង្វែងទៅ ឯស្រស់ស្រីពៅនាងនួនល្អង
នាងមានគភ៌គ្រប់ខែហើយហោង នួនល្អងថ្នាក់ថ្នមមិនឲ្យអាក់ ៗ
លុះគ្រប់ខែដប់ប្រសប់បុះ ប្រសូតកូនប្រុសល្អសមស័ក្តិ
យកតាមនិមិត្តទាំងមកដាក់ វរលក្ខណ៍ឲ្យឈ្មោះចៅពលឯក ៗ
លង់លុះគន្លងឆ្នាំមួយពីរ នារីនាងមានគភ៌ឥតប្លែក
ប្រសូតកូនប្រុសល្អបំផ្លែក ឲ្យនាមយ៉ាងឯកអនុជា ៗ
ឯបុរសប្តីនឹងប្រពន្ធ ទៀយហត់ពេកលន់រាល់វេលា
ព្រួយតែនឹងរកស្បៀងអាហារ លំបាកវេទនាព្រោះអត់ឃ្លាន ៗ
រីឯកុមារទាំងពីរនាក់ ឪពុកធ្វើធ្នូមួយម្នាក់បាន
ដើរបាញ់បក្សីក្នុងសំសាន ឆ្ងាយចេញពីស្ថានផ្ទះអាត្មា ៗ
ចេញទៅត្រឡប់វិញរាល់ថ្ងៃ ពុំដែលខានទេពីរកុមារ
លុះដល់ថ្ងៃក្រោយមួយទៀតណា ចូលក្នុងព្រឹក្សាលេងសប្បាយ ៗ
ចូលក្នុងព្រៃជ្រៅស្ងាត់ត្រឈឹង ប្រាប់ថាព្រលឹងមាសបងអើយ
មើលផ្លែពលឯកល្អម្ល៉េះហើយ រលោងស្មើរស្រក់ទឹកបុះមក ៗ
ចាំដល់បងធំរកប្រពន្ធ ដូចផ្លែពលឯកបានបងយក

បើមិនបានដូចទេពនូក ម្ដាយរកបង់រត់ចោលគាត់ហើយ ៗ
និយាយនឹងប្អូនពាក្យប៉ុណ្ណឹង ប្អូនគិតជញ្ជឹងឥតមានស្បើយ
លុះដល់មកផ្ទះប្រាប់ម្ដាយហើយ ថាអ្នកម្ដាយអើយបងគាត់ថា ៗ
តែដល់គាត់ធំរកប្រពន្ធ រូបល្អលើសលន់ទើបបានការ
ដូចផ្លែពលឯកលើព្រឹក្សា មិនបានកាលណា គាត់រត់ចេញ ៗ
ម្ដាយឮកូនតូចប្រាប់ដូច្នោះ ខឹងញ័រក្នុងពោះដើរបណ្ដេញ
អាឯងកុំនៅចូលនឹងអញ បើអាស្រឡាញ់អារកចុះ ៗ
អញរកមិនបានល្អបំឡែក ដូចផ្លែពលឯកទេកូនប្រុស
បើឯងរកបានទៅរកចុះ មិនថាទេប្រុសថ្លៃមាសម្ដាយ ៗ
អ្នកណាចិត្តធំមិនស្ដាប់អញ ចូរបាថយចេញអញមិនស្ដាយ
កុំនៅឲ្យអញក្ដៅក្រហាយ កូនមិនស្ដាប់ម្ដាយចេញឲ្យឆាប់ ៗ
ឯកុមារជាបងនោះ ឮម្ដាយបន្ទុះបន្ទោសសាប
កាន់កាំបិតព្រាចេញប្រញាប់ ក្រឡាប់វិលវៃចូលព្រៃជ្រៅ ៗ
ឯប្អូនឃើញបងរត់ទៅច្បាស់ អាល័យបងណាស់រត់តាមទៅ
ទាន់បងត្រង់ពាក់កណ្ដាលផ្លូវ បណ្ដើរគ្នាទៅគាត់ព្រឹក្សា ៗ
លុះពេលថ្ងៃល្ងាចមេឃស្រទំ ពពកបាំងក្នំព្រះសុរិយា
កុមារទាំងពីរខំយាត្រា លេចកាលហើយណាចូលព្រៃធំ ៗ
ថ្ងៃនោះជួនជាមេឃងងិត ពពកបាំងបិទងងិតក្នំ

ផ្គរសព្ទទិសាព្រៃគ្រមៗ　　កុមារតូចយំរកម្ដាយ ៗ
ទំនួញថា៎ឱ! អ្នកម្ដាយអើយ　　កូនឃ្លាតឆ្ងាយហើយពីអ្នកម្ដាយ
ភ្លៀងរងាខ្លាំងញ័រអស់កាយ　　ម៉្លេះសមអ្នកម្ដាយមើលផ្លូវកូន ៗ
ឯបងព្រួយប្អូនយំសោយសោក　　វិយោគក្នុងព្រៃឈឹងស្ងាត់សូន្យ
ខ្លោចផ្សាក្នុងចិត្តអាណិតប្អូន　　លោមថាមាសស្ងួនកុំយំស្រែក ៗ
ចាំបងពួតភ្លើងបង្កាត់ឲ្យ　　ប្អូនអើយកុំឲ្យរងាពេក
បងធ្វើដំរំឲ្យប្អូនដេក　　កុំយំខ្លាំងពេកអាណិតបង ៗ
លួងប្អូនហើយស្រេចកាប់មែកឈើ　　ដាក់ពីខាងលើស្រេចដាម្ដង
ពួតភ្លើងបង្កាត់ផេះបានហោង　　កំដៅឆ្អឹងខ្នងសព្វរៀងកាយ ៗ
យប់ជ្រៅបន្តិចភ្លៀងក៏រាំង　　កុមារទាំងពីរសុខសប្បាយ
បានភ្លើងផេះខ្លាំងកំដៅកាយ　　ភ្លេចនឹកដល់ម្ដាយបានដេកលក់ ៗ
កុមារទាំងពីរអស់កំឡាំង　　ស្មារតីកាន់កាំងស្ងូរស្រមុក
បានភ្លើងក្ដៅ ៗ ផេះគគុក　　គគុលដេកលក់ដរាបព្រឹក ៗ
ភ្ញាក់ឡើងគិតគ្នាធ្វើអន្ទាក់　　វេញខ្សែពីរនាក់ឲ្យសន្ធឹក
ធ្វើជាអន្ទាក់ដាក់សត្វម្រឹគ　　លុះដល់ពេលព្រឹកយើងទៅមើល ៗ
កុមារទាំងពីរកាប់ឃ្លាយមក　　សកយកសម្បកបានទៅហាល
ហើយសកយកតាំងសម្បកព្រាល　　អន្ទងដំដាលទន់ល្វន់ល្ហាស ៗ
វេញខ្សែរួចហើយធ្វើអន្ទាក់　　បានយកទៅដាក់ច្រើនពេញពាស

ស្រាស់ជាប៉ែក ៗ មែកឈើក្រាស់ អន្ទាក់ពេញពាសអស់តាំងព្រៃ ៗ
រីឯពួកម្រឹគឈ្លូលរមាំង ជ្រូកក្ដាន់ប្រើសទ្រាយទន្សាយក្ដី
ចូលក្នុងអន្ទាក់ជាប់ច្រើនក្រៃ ក្សិណក្ស័យជីវិតឥតគណនា ៗ
លុះដល់ព្រឹកព្រាងអរុណោទ័យ កុមារពីរថ្ងៃចរយាត្រា
ទៅមើលអន្ទាក់ដាក់នៅនា ដងអរញ្ញច្រើនក្រាស់ក្រៃ ៗ
ឃើញពួកសត្វម្រឹគជាប់គគោក ស្ទាប់ក្នុងអន្ទាក់នោះឯងនៃ
នាំគ្នាកាប់ស្នែងសែងវិលវៃ មកដល់នាពួកខ្ទែងខ្លួន ៗ
ធ្វើជាចង្កើរមួយយ៉ាងធំ ដុតភ្លើងដង្គុំឆេះមាំមួន
លើកសត្វធំ ៗ ដាក់សំនួន ខំប្រឹងថែរក្សួនចង្កើរសាច់នោះ ៗ
លុះចង្កើរឆ្អិនស្រេចពីរកុមារ បានបរិភោគក្ដាឆ្អែតពេញពោះ
សាច់ចង្កើរច្រើនពេកស៊ីពុំអស់ លើកសាច់ចង្កើរនោះទើទុកទៅ ៗ
រីឯសាច់ចង្កើរក្លិនឈ្ងុយឈ្ងប់ ខ្យល់បក់ត្រឡប់សព្វទិសា
ធុំក្លិនដល់ក្រុងអសុរា ជាស្ដេចយក្សនៅក្នុងព្រៃ ៗ
យក្សនោះមានឫទ្ធិអំណាចខ្លាំង មិនហ៊ានតតាំងនឹងគេដៃ
ចាក់បបខ្ចបខ្ចាចព្រះបារមី ក្រុងអសុរីមានបុណ្យខ្លាំង ៗ
ព្រោះមានសម្បត្តិបួនប្រការ ឆ្នាំងឆ្អិនឯងណាកន្ទ្រង់បោយ
ខ្សែចងឯងផងពំបណ្ដាយ ដេញវាយពីក្រោយដកបកាប ៗ
ស្ដេចមានសម្បត្តិបួនប្រការ គ្មានយក្សឯណាមកផ្ទឹមប្រៀប

យានទៅត្រង់ណា សឹងឱនក្រាប    សិរសាទន់ទាបរាបដល់ដី ៗ
មិនខ្លាចតែត្រឹមយក្សប្រុស ៗ    ខ្លាចនោះរហូតយក្សស្រី ៗ
ដំណើរស្ដេចយានព្រះបក្រី    ទៅបំយក្សស្រីភ័យបំប្រប់ ៗ
ហេតុតែគ្នាខ្លាចអំណាចពេក    ដោយបុទ្ធបារមីខ្លាំងលើសលន់
ស្ដេចយក្សត្រូវខាតបង់ទ្រព្យធន    ឲ្យខ្លួនអាប់អន់ធនបានគេ ៗ
វេលាជុំកិនសាប់ផ្អើរនោះ    ពាល់ត្រូវច្រមុះយក្សរិះរេ
នរណាផ្អើរសាប់ឈ្ងុយម្ល៉េះទេ    ថាមេអញអត់ទ្រាំពុំបាន ៗ
គិតស្រេចស្ដេចចាប់ដំបងពេជ្រ    ហោះហិចកណ្ដាលអាកាសស្ថាន
ផ្លេកផ្លោះសំដៅទៅហិមពាន្ត    យក្សចុះឈរឈរ នឈប់រោ ៗ
យក្សអើតផ្អៀងផ្អងរេងើបងើយ    ទៅមុខថយក្រោយសព្វទិសា
ទៀបទីបផ្អើរកុមារ    យក្សឃើញហើយណាក៏លាន់មាត់ ៗ
ថាឃើអើ! នេះពេញមានលាភ    ជាមហាភ័ក្ដធំក្នុងព្រៃស្ងាត់
សាប់ផ្អើរស្រាប់ ៗ មានគ្រប់សព្វ    ស៊ីឈ្ងុយសម្ងួយម៉ាត់ឲ្យដឹងចិត្ត ៗ
យក្សពមពាំងក្បាលពមពាំងជើង    ឈ្ងុយសម្ងួយរញៀវឡើងទៅក្នុងមាត់
ទំពាគ្រប់ ៗ ដូចគេកាត់    អស់ពីក្នុងមាត់ថែមមួយទៀត ៗ
ឯកុមារបង់ក៏មិននៅ    ព្រឹកព្រានដើរទៅមើលអន្ទាក់
រីឯប្អូនតូចនៅតែម្នាក់    អង្គុយមើលយក្សស៊ីសាប់ផ្អើរ ៗ
យក្សស៊ីរួចហើយហិចហោះទៅ    ទីស្ថានលំនៅប្រាង្គណ៍ប្រសើរ

ឯកុមារប្អូនមើលសាច់ឆ្អើរ លើឆ្អើយក្រស៊ីអស់គ្មានសល់ ៗ
ឯកុមារបងត្រឡប់វិញ កង់ពោះខ្វល់ខ្វាញ់ឃ្លានខ្វាយខ្វល់
ប្រញាប់រួតរះឲ្យឆាប់ដល់ បរិភោគស្កប់ស្កល់សាច់ឆ្អើរនោះ ៗ
មកដល់កាលណាក្រឡេកមើល សាច់លើចឆ្អើររលីនអស់
សាច់ឆ្អើរទៅណានៃប្អូនប្រុស ម្ដេចអស់ប្អូនប្រាប់បងឲ្យដឹង ៗ
ប្អូនក៏ចចារប្រាប់បងខ្នី មិនដឹងជាអ្វីបងកុំខឹង
ប្អូនភ័យពេកក្ដាត់ថ្មាត់ព្រលឹង សត្វទឹងបង្គួមរោមបង្កា ៗ
បុះពីអាកាសកាន់ដំបង អង្គុយប្រហោងស៊ីមំសា
មិនមានកោតខ្លាចអាចបេស្ដា ស៊ីរួចយាត្រាហិចហោះទៅ ៗ
ប្អូនអ៊ីយបងព្ទចាស់លោកថា មានពុកបក្សាបង្គួមករ
ពុកមាត់ស្រមាមរោមស្រមូវ ចាស់ ៗ លោកហៅថាយក្ស ៗ
យក្សនោះចិត្តកាចក្រៃណាស់ លោភោទោសោមោហោណា
កាលួចកាច់ឥតមេត្តា នឹងហើយយក្សណាមាសបង ៗ
ប្អូនព្ទបងប្រាប់សត្វសេចក្ដី ដឹងហើយអន់ភ័យភីតខ្លាចផង
សារស័ព្ទដំណើរដោយដើមទង សត្វត្រប់ហើយហោងប្អូនសុខចិត្ត ៗ
ឯបងនាំប្អូនចូលព្រៃជ្រៅ ដើររកកាប់ផ្ដៅប្រែនក្រៃពិត
នាំគ្នាពុះជ្រៀកឲ្យល្អិត ៗ ទើបយកមកបិតទុកធ្វើជុប ៗ
តាំងពីរកុមារខំប្រឹងធ្វើ បងចាក់ខាងលើប្អូនប្រឹងមុប

ខំប្រឹងហូតផ្តៅខាងកង្កុច ប្រឹងទាក់ប្រឹងមុចទាល់តែហើយ
កុមារធ្វើជុចធំក្រៃលែង ធំហើយវៀនវែងឥតផ្ទឹមឡើយ
ដាក់ចោលនៅសៀមធ្វើព្រងើយ សម្រេចដល់ហើយផ្តៅដប់បាច់
រឿងនេះខ្ញុំស្ទះឈប់ចចារ ថ្លែងពីអសុរាយក្សបន្តិច
ដែលវាធ្លាប់មកបានស៊ីសាច់ វានឹកមិនភ្លេចមួយវេលា
រីឯស្តេចយក្សដល់ពេលឃ្លាន នឹកដល់ហោមពាន្តអរញ្ញា
ចាប់ដំបងខ្ចីរយាត្រា ហោះលឿនអស្ចារ្យដល់កន្ទ្វែង
ស្រេចហើយយក្សបរពុះសំដៅ ដល់អន្គុយនៅធ្វើបំបែង
ហៅទៅកុមារជាព្រះស្តែង កុមារតូចឯងធ្វើអ្វីអេះ
កុមារទាំងពីរតបឆ្លើយជូន តនឹងយក្សផ្គង់ដោយតម្រិះ
ថាតាអ៊ឹយតាខ្ញុំធ្វើនេះ ហៅជុចខ្វិះរកដាក់សត្វ
រមាសរមាំងប្រើសទន្សាយ ឈ្លូសទ្រាយប្រមាខ្លាដើរកាត់
ឲ្យតែចូលជុចជាប់គ្រប់សត្វ តែហ៊ានបោលកាត់ជាប់ជុចខ្ញុំ
យក្សថានែទៅជុចប៉េនប៉ុន ម្តេចអួតថាជាប់សត្វធំៗ
ប៉េនប៉ុនដូច្នេះទៅអ៊ឺយកុំ មិនជាប់សត្វធំទេណាទៅ
ឯសត្វអស់នោះវាខ្លាំងណាស់ វាប៉ិនប្រមាសណាស់ពេកគ្រូ
បើទៅមិនជឿក្តាល់ឥឡូវ តាត្បុលចូលទៅល្បងជុចមើល
ប៉ុណ្ណឹងបើតាវេត្រួច ទៅតិះដៀលចុះថាតាព្រិល

ចាស់អ៊ើអ៊ុំនួតអួតឯងឆើល  ចាស់ព្រើលមិនគិតប្រយោគរូប
បើតាបម្រាសផុចហៅផាច់  តើហៅសម្រេចឲ្យអ៊ីហូប
ថាឲ្យប្រាកដចំពោះរូប  ឲ្យម្ហូបបុះហៅឲ្យអ៊ីតា ៗ
កុមារពីរស្តាប់យក្សអធិប្បាយ  កុមារដោះស្រាយដោយប្រាជ្ញា
ខ្ញុំមានសាប់ផ្អើរជូនពីសា  ចូលជុចចុះណាលោកតាអ៊ឹយ ៗ
យក្សបួលកន្ទុំជុចក្បាលទៅមុខ  ចូលហួសផ្លូវស៊ិនផុតដើងហើយ
បម្រាសពុំរួចស្រែកយ៉ើយ ៗ  ថាចុះហៅអ៊ឹយអាណិតទៅ ៗ
កុមារទាំងពីរកាន់ផ្តៅចាំ  ខ្ញុំប្រឹងថែទាំអគ្គយនៅ
ផាច់ផួសផាច់ផួសថែមទៀតទៅ  រឹងខ្លួនរឹងក្បៀវពុំរួច ៗ
កុមារទាំងពីរថាតាអ៊ឹយ  ម្តេចឡើយថ្ងៃមុនតាហ៊ានលួច
ស៊ីប្រឹទម្ទឹង ៗ ពុំរួច  ម្តេចតាហ៊ានលួចសាប់ផ្អើរខ្ញុំ ៗ
កុមារតួចទាញចាប់ពុកមាត់  យកទៅចងព័ទ្ធនឹងឈើធំ
ទាញរឹតយ៉ាងតឹងយក្សស្រែកយំ  ថាហៅកុំ ៗ អាណិតតា ៗ
កុំរឹតខ្លាំងពេកឈឺតាណាស់  អាណិតតាចាស់ណាហៅណា
របោចរបេះពុកចង្កា  ហៅកុំលេងតាជូនដៃពេក ៗ
កុមារបងចាក់ចង្កេះយក្ស  បែបដូចជាភ្ញាក់យកប្រឹងស្រែក
កុមារប្អូនយកដៃរុកក្លៀក  យក្សស្រែកស្ទើរបែកត្រែត្រឹកក្បា ៗ
យក្សអង្វរហើយអង្វរទៀត  ល្មមហើយលោកហៅអាណិតតា

ផាច់ខ្យល់ឥឡូវទៅហើយណា    អាណិតមេត្តាតាសូមសុំ    ៗ
ចៅអើយ ៗ ចៅសូមមេត្តា    ចុកណែនទ្រូងផ្សាទុកក្រម
ឈឺអស់សព្វសាច់ដូចគេដំ    ចៅអើយតាសុំអត់ទោសតា    ៗ
បើចៅលែងតាក្នុងពេលនេះ    តាឲ្យទ្រព្យថ្លៃជូនប្រការ
ខ្សែចងដំបងពាយឯងក៏    កន្សែងបោយណាឆ្នាំងធ្នូឯង    ៗ
កុមារថាបើពាក្យតាពិត    ដូចជាតាគិតខ្ញុំនឹងលែង
ខ្សែចងដំបងនឹងកន្សែង    តាំងឆ្នាំងធ្នូឯងខ្ញុំលែងភ្លាម    ៗ
ចៅអើយពាក្យតាជាប្រាកដ    ចៅលែងតាចុះកុំទីមទាម
តាមតាទៅចុះតាជូនភ្លាម    មិនឲ្យទាក់ទាមទេណាចៅ    ៗ
កុមារទាំងពីរកាត់ផ្តៅស្រេច    អស់មួយរំពេចគ្មានសល់នៅ
យក្សក្រោកអង្គុយឡើងប្រងូវ    ថាចៅអើយចៅតាបានរស់    ៗ
ឥឡូវតាផ្តាំចាំឲ្យដាក់    ចៅទៅស្រុកយក្សទិសឯណោះ
អញ្ជើញទៅក្រោយតាមតាចុះ    ស្រុកនោះមិនឆ្ងាយប៉ុន្មានឡើយ    ៗ
បីថ្ងៃនៅខាងទិសឦសាន    ចៅមុខជាបានដល់តាហើយ
តាលាទៅមុនចៅទៅក្រោយ    តាធ្វើផ្លូវឲ្យចៅស្រួលដើរ    ៗ
យក្សនោះចេញផុតពីកុមារ    ខ្នីឃ្នាតយាត្រាដកដើមឈើ
ខំត្រាយត្រួសផ្លូវឲ្យចៅដើរ    យក្សខំប្រឹងធ្វើដល់នគរ    ៗ
លង់លុះដល់ព្រឹកព្រះសុរិយា    ទាំងពីរកុមារយាត្រាចរ

ក្នុងព្រៃហោមវាព្រឹក្សាក៏ សំដៅនគរក្រុងអសុរី ៗ
ឃើញព្រៃព្រឹក្សាដុះជាជួរ មុខគួរឲ្យមើលលេងប្រុសថ្លៃ
ស្រឡិតដុះជិតដើមស្រឡី ឈ្នាញត្រីដុះជិតជិតដើមត្រាច ៗ
គគីរដុះនៃបអែបគគិត ឈើទាលដុះជិតក្រពេញពង
ស្រឡៅស្រល្ពួតខ្ពស់បំញាប កញ្ជើបាយដាចជិតមាក់ដោក ៗ
មាក់ប្រាងដុះជិតជិតមាក់ប្រេង ដើមបេងដុះបៀតដើមកកោះ
លំពាន់រាវ៉ណ្ដទីងលំពោះ ចន្ទន៍ត្រសក់ដុះជិតដើមក្រឹស្នា ៗ
ប្អូនអើយប្អូនមើលដើមក្រូបក្រាយ ដាជួររៀងរាយណាកែវណា
ឈើច្រើនព័ណ៌ណាស់ក្នុងព្រឹក្សា មិនឈ្នះពណ៌នាទេប្រុសបង ៗ
កុមារទាំងពីរខំប្រឹងត្រាច់ បីថ្ងៃសម្រេចដូចបំណង
ដល់ស្រុកយក្សាស្រេចហើយហោង ចរចូលជាម្ដងក្នុងវាំងវៃ ៗ
ស្ដេចយក្សត្រាថាកុមារមក ខំស្ទុះងើបក្រោកចេញពីក្នុង
ទទួលកុមារទាំងពីរពង្ស ស្ដេចរៀបប្រៀបប្រុងគ្មានខ្វះអ្វី ៗ
ក្រាលពូកព្រៃព្រំបៀមបំផង រនាំងវាំងននដូចម្ដេចក្ដី
កន្ទេលខ្នល់ខ្នើយល្អថ្មីៗ បក្រិឲ្យក្រាលគ្រែសយនា ៗ
អញ្ជើញកុមារទាំងពីរពង្ស ឲ្យចូលទៅស្រង់រសគន្ធា
លំអិតខ្ចឹមបន្ទន់ប្រស់ក្រឹស្នា រាវីរង់ថ្វាក្រអូបសាយ ៗ
ស្រង់ស្រេចស្ដេចឲ្យផ្លាស់ព្រះពស្ដ្រ អង្គកុមារាទាំងពីរកាយ

ស្ដេចឲ្យអញ្ជើញក្រយាបាយ គោជនទាំងឡាយពេញគ្រៀបគ្រា ៗ
បរិភោគហើយស្រេចស្ដេចឲ្យផ្ដុំ លើពូកព្រៃព្រំទីសុវណ្ណា
ដោយអស់កំឡាំងព្រះកាយា និទ្រាលក់លង់ពុំដឹងប្រាណ ៗ
ទាំងពីរកុមារក្រោកនិទ្រា ចុះចាកសុវណ្ណា មាសកល្យាណ
ពួកយក្សគង់គាល់ក្នុងរាជស្ថាន ស្ដេចយក្សក៏មានពាក្យពោលថា ៗ
ហៃបាទាំងពីរបងនឹងប្អូន យើងសុំជាកូនណាប្រុសណា
កុំកូនប្រែកែកនឹងបិតា បានរសជីវ៉ាពីកូនឯង ៗ
ឪពុកដូចបានកើតម្ដងទៀត បាវើយប្រាកដពិតជាក់ស្ដែង
ឪពុកកុំបានតែបាឯង ម្ល៉េះសមចម្បែងស្លាប់បង់ម្សៀត ៗ
គ្មានអ្នកណាដឹងពោលក្នុងព្រៃ អាសោចពេកក្រៃដូចសត្វធាតុ
ពេលនេះដូចជាកើតម្ដងទៀត កុំអីបង់ជាតិបង់ជីវ៉ា ៗ
ស្ដេចមានបន្ទូលរំលឹកគុណ កុមារតូចតន់ទាំងទ្វេហា
សរសើររូបស្រេចឲ្យតារថា ឲ្យប្រុសកុមារបានសោយរាជ្យ ៗ
ពេលនោះស្ដេចទ្រង់ប្រទានឲ្យ កន្សែងបក់បោយនោះឯងអាច
ឆ្នាំងឆ្កិនឯងធំដោយអំណាច ខ្សែចងដំបងវាយឯងណា ៗ
ទាំងពីរកុមារលើកហត្ថឡើង ទទួលពរពីធម្មបិតា
ទទួលព្រមទាំងទ្រព្យថៃថ្លា ទាំងប្អូនប្រការបិតាឲ្យ ៗ
ឯក្រុងអសុរីសួរនាមបុត្រ ឈ្មោះអ្នកប្រាកដប្រាប់កុំភ្លាយ

ឈ្មោះអ្វីទៅព៎ណាកូនអើយ ក្រែងដល់ថ្ងៃក្រោយមានទុក្ខភ័យ ។
ឪពុកលើកពលទៅជួយណា ក្រែងកូនមានការអាសន្នអ្វី
ពួកពលបិតាច្រើនក្រាស់ក្រៃ កុំឲ្យភិតភ័យតទៅមុខ ។
កុមារលើកហត្ថពីរទូលថា បពិត្របិតាបូរចាំទុក
ដំណពីនេះតទៅមុខ ខ្ញុំនាមឈ្មោះថាចៅពលឯក ។
ឯប្អូនខ្ញុំនោះឈ្មោះអនុជ បាននាមពីមាតាបិតា
ឯនាមឈ្មោះទាំងពីរនេះណា ចាំចុះបិតាកុំឲ្យភ្លេច ។
កូនសូមក្រាបទូលបិតាផង នាមបិតាហៅឈ្មោះដូចម្តេច
ដំណទៅមុខក្រែងមានកិច្ច រឿងរ៉ាវម្តេចៗកូនបានដឹង ។
ឯនាមឈ្មោះយើងជាឪពុក បារ៉ុយចាំទុកប្រុសព្រលឹង
យើងប្រាប់ឲ្យបញ្ជាក់ក្នុងគ្រាហ្នឹង ចាំចុះព្រលឹងឈ្មោះបិតា ។
វិរុឡ្ហមាត្យក្រុងអសុរី នាមអគ្គមហេសីស្រីចន្ទ្រា
បុត្រីនាងច័ន្ទបុទុមា ក្រុងព្រះសោមាពេជ្របូរី ។
ហៃបាទាំងពីរចាំឲ្យជាក់ ឪពុកប្រាប់អ្នកសព្វសេចក្តី
ក្រែងដល់ខាងមុខបាមានភយ ចូលមកបុរីប្រាប់បិតា ។
ទាំងពីរកុមារនឹងអសុរ ប្រាប់សព្វសេចក្តីគ្រប់ប្រការ
ទៅវិញទៅមកពីនាមា ប្រាកដប្រជាគ្មានបន្ទោះ ។
កុមារទាំងពីរថ្វាយបង្គំ បិតាមាតាព្រមទាំងអស់

បពិត្របិតានៅនេះចុះ　　កូនថ្វាយបង្គំលាសិនហើយ ៗ
ក្រុងអស្សុរីត្រកូនលា　　ថ្ងៃជាថ្ងៃមាសឪពុកអើយ
ប្រុសកុំនៅយូរណាអ្នកអើយ　　ប្រុសអើយឆាប់វិលត្រឡប់ក៏ ៗ
ៈហពីរកុមារបាឈប់សិន　　កុំអាលប្រញាប់ឆាប់យាត្រា
ចូលស្តាប់បណ្តាំយើងបិតា　　គិតការដំណកទៅទៀត ៗ
ទ្រង់មានបន្ទូលនឹងមហេសី　　ជានៃស្រីថ្ងៃជួយជុះឆ្ងៀត
បងចង់គិតការបន្តិចទៀត　　កុំឲ្យផុតជាតិត្រកូលយើង ៗ
ចន្ទបទុមាបុត្រនេះ　　ផ្សុំផ្គុំនឹងកូនឲ្យចុំចើង
ត្រង់ពជ្ឈបូរីបានរុងរឿង　　លុះអស់ពីយើងទៅកាលណា ៗ
បពិត្រស្វាមីម្ចាស់ខ្ញុំអើយ　　បន្ទូលត្រូវហើយរៀមជេដ្ឋា
បំណែកនាងចន្ទបទុមា　　ជីតាអាយុបានដប់ឆ្នាំ ៗ
ប្រាំមួយវស្សាទៀតទើបគ្រប់　　ប្រសប់ចួបចប់តាមបំណាំ
គ្រប់ជាប្រាំមួយដណ្តប់ឆ្នាំ　　ដាក់ផ្កាកូនយើងទៅទៀតបាន ៗ
ពន្ទុកពន្ទៃស្រីចន្ទ្រា　　ថ្ងៃថ្វានាងហៅកូនកល្យាណ
ចន្ទបទុមាពីក្នុងស្ថាន　　ឲ្យបានបុត្រាឃើញប្រាកដ ៗ
ទ្រង់ត្រាស់ឲ្យហៅមកដល់ហើយ　　ជាហៃកូនខ្ញើយចូលតាមបទ
កុមារទាំងពីរនេះសន្តត　　ប្រាកដជាបងកូនឯងហើយ ៗ
ឲ្យធ្វើបម្អូនប្រាំមួយឆ្នាំ　　គ្រប់តាមបណ្តាំបិតាក្រោយ

ហួសពីនោះទៅអភិសេកឲ្យ　　គ្រប់គ្រងបុរីពជសេមា　ៗ
ឥឡូវគ្រាន់តែផ្តែផ្តាំទុក　　ចាំពាក្យឪពុកណាកូនណា
ព្រោះពុំទាន់គ្រប់ព្រះជន្ម　　បិតាផ្សែផ្សំទុកជាមុន　ៗ
ចន្ទុបទុមានាងក្មេងណាស់　　វរពជក្សត្រីយ៍ស្រីអៀនអន់
ក្នុងព្រះបិន្ទាស្រឡាញ់លន់　　មិនហ៊ានគយគន់ផាក់កក្រៅ　ៗ
ក្សត្រីយ៍លបទតបុងព្រះនេត្រ　　មិនឲ្យដឹងហេតុដល់អ្នកណា
ឃើញទ្រង់អង្គព្រះកុមារ　　ក្តួលក្នុងទភញ័ររំប្រប់　ៗ
ឯព្រះកុមារទតនាងផាក់　　ដូចគេកន្ទ្រាក់កន្ត្រជួលជ្រប់
ក្នុងចិត្តស្រឡាញ់នាងលើសលប់　　ប៉ុន្តែប្រឹងផ្ទប់ធ្វើព្រងើយ　ៗ
បិតាមាតាឲ្យពរថា　　ឲ្យបានសុខាមូលគ្នាហើយ
គ្រងរាជសម្បត្តិទៅខាងក្រោយ　　កុំឲ្យសត្រូវមកបៀតបាន　ៗ
ក្រុងពេជ្របុរីមានអំណាច　　នរណាក៏ខ្លាចមិនអាចហ៊ាន
សម្បត្តិទាំងបួនប្រការមាន　　ប្រធានគរកូនឯងហើយ　ៗ
ឯកុមារប្អូនចាំឪពុក　　នឹងគិតដាក់ទុកទៅខាងក្រោយ
គ្រប់ប្រាំមួយឆ្នាំបងឡើងសោយ　　កុមារប្អូនឲ្យធ្វើឧបរាជ　ៗ
ពលរេហ៍ទាំងអស់ជាចំណុះ　　ឲ្យតាំងនៅចុះក្រោមអំណាច
ប្រាំមួយឆ្នាំទៀតបងសោយពង្ស　　កូនប្អូនឧបរាជកាន់រេហ៍ពល　ៗ
លុះចប់បណ្តាំស្រេចហើយណា　　អង្គព្រះកុមារនឹងខ្វាយខ្វល់

អាណិតក្សត្រិយ៍ស្រីនិមល ពុំដែនកិច្ចកលដល់តិចឡើយ ។
បពិត្រតាំងទូទីស្នេហា មាតាបិតាម្ចាស់កូនអើយ
កូនថ្វាយបង្គំលាសិនហើយ ដល់ពេលខានក្រោយកូនវិលវិញ ។
ចន្ទបុត្រាមាសបងអើយ នៅចុះប្អូនអើយកុំទុកម្នេញ
នៅឲ្យសុខាកុំកន្ទេញ បងឆាប់វិលវិញទេណាពៅ ។
នាងឮព្រះវៀមផ្តាំផ្ដូរប្ដោះ ផ្អកផ្អឹសក្នុងពោះស្រស់ឆោមឆៅ
ញាប់ញ័របំប៉ប់ស្រស់ស្រស៊ើ នាងគង់នែបនៅជិតមាតា ។
ទាំងក្រុងអសុរីព្រះបិតុរេត ទាំងស្រីបន្ទោព្រះមាតា
ទ្រង់ព្រះកន្សែងថ្ងូរសោកា ទំនួញទ្ងូញថាមាសម្ដាយអើយ ។
កូនអើយថ្ងៃទៅកុំនៅយូរ ទ្រង់ម្ដាយគ្មានជូរដល់តិចឡើយ
អសុរីបិតាចាស់ណាស់ហើយ កូនអើយប្រញាប់ឆាប់រួសរាំ ។
កុមារលាស្រេចទាំងពីរព្រាណ ចរចេញចាកបានផុតសេមា
ចូលក្នុងព្រៃព្រឹក្សទឹកខ្វាបផ្កា ដល់ព្រះបិតាមាតាថ្ងៃ ។
ទឹកដល់នាងច័ន្ទបុត្រា ម៉េះសមពុំឆ្អានទឹកស្រមយ៍
ដល់បងដឹងអើយណាមាសថ្ងៃ ម៉េះសមសាវស្រែសស្រែនទឹក ។
ណ្ហើយចុះប្អូនអើយយើងទំស្រូត ខំរូតដំណើរក្នុងព្រៃព្រឹក្ស
ឯចិត្តវៀមបងវែងរឭក ទឹកដល់នាងច័ន្ទបុត្រា ។
ណាចិត្តមួយនឹកអគ្គម្ដាយ ឥពុកនៅឆ្ងាយណាប្រុសណា

ដូច្នេះសង្ឃឹមខំយាត្រា　　ឃើញមុខមាតាបិតាយើង ៗ
ប្អូនអើយខំស្រូតរូតដំណើរ　　ប្រុសអើយខំដើរបន្តិចទៀត
ឲ្យឆាប់បានដល់ទៅស្រុកយើង　　នឹងបានចុំពេ្កងឪពុកម្ដាយ ៗ
ទៅដល់កាលណាបក់កន្ទេ្យង　　ប្រាថ្នាឲ្យបានទ្រព្យសម្បាយ
មាសប្រាក់កែវកងធងទាំងឡាយ　　លើកជូនអ្នកម្ដាយឪពុកយើង ៗ
កុមារទាំងពីរដើរតែដើរ　　គំនិតគិតធ្វើឲ្យរុងរឿង
ប្រដាប់សព្វគ្រប់ឲ្យមានឡើង　　ដំកុំដំកើងជូនមាតា ៗ
ហេតុតែបុត្រកម្ពាព្រេង　　ត្រូវឲ្យវង្វេងបែកបាកគ្នា
ព្រាត់ប្រាស់បងប្អូនក្នុងព្រឹក្សា　　កម្ពាមទាន់ណាក្នុងគ្រានេះ ៗ
ឯកុមារបងយកកន្ទេ្យង　　ប្រាថ្នាចង់បក់ឲ្យកើតសេះ
អស្សពាហ៍មួយមកគ្រាន់នឹងជិះ　　ជាយានជំនិះតទៅទៀត ៗ
បន្ទាស្បូវសក្រាតមុតបាទា　　ពុះពង់ខ្លាបផ្កាក្នុងព្រៃញាត
ត្បូលក្នុងប្រកជ្រៅផ្លូវបង្អៀត　　ខំដើរទៅទៀតពុំរួចឡើយ ៗ
ទើបយកកន្ទេ្យងបក់មកណា　　កើតរូបអស្សពាហ៍ប្រាកដហើយ
ទើបបងឡើងជិះធ្វើព្រើយ　　អនុជដើរក្រោយបន្តិចទៅ ៗ
ស្រាប់តែព្យុះខ្យល់មេឃងងិត　　ពពកបាំងបិទមើលពុំយល់
ធ្លាក់ភ្លៀងខ្លោកៗ ជ្រុះមកដល់　　កុមារប្រឹងរុលរត់តាមសេះ ៗ
កុមារប្រឹងរត់តាមពុំទាន់　　គិតថាឪអញរង្គាមួះ

ណាមួយព្រួយទឹងបាត់ផានសេះ    រាបេះតែលុនលឿនបាត់ទៅ ។
ពុស្ទូរល្ហើយ ៗ ខំកាត់រក    ជ្រៀតជ្រែកគិតស្ម័គ្រហាក់មាត់ហៅ
មិនដឹងជាសត្វខំរត់ទៅ    ខំប្រឹងស្រែកហៅពុំពុឆ្លើយ ។
បងអើយ ៗ បងម្តេចចោលប្អូន    ដិះសេះបាត់ស្ងួនចោលប្អូនហើយ
ម្តេចមិនគិតប្អូនដល់តិចឡើយ    ឲ្យប្អូននៅក្រោយទឹងនរណា ។
មានតែដើមឈើនៅក្នុងព្រៃ    គ្មានទីដំរីសឹងគជសា
ម្តេចហ៊ានះចោលប្អូនឲ្យវេទនា    កោតចិត្តរៀមរ៉ាមិនអាសូរ ។
រឿងប្អូនខ្ញុំស្ទះត្រឹមណេះសិន    ថ្លែងពីកុមារបងចាំយូរ
ត្រឡប់សេះវិញខំគិតគូរ    ថាប្អូនម្តេចយូរពុំឃើញមក ។
ស្រែកហៅថាអើយប្អូនអើយប្អូន    ម្តេចបាត់ឈឹងស្ងួនបងខំរក
វង្វេងបាត់ផានបានមិនមក    ថ្ងៃអើយរកបងក្នុងស្ថានណា ។
ខំស្ទះស្វែងរកសព្វដងព្រៃ    ពុំឃើញឡើយនៃក្តួលនុរា
បណ្តូលបណ្តាច់មាសដីរ៉ា    កនិដ្ឋាម្តេចឡើយពុំឆ្លើយបង ។
ឱហេតុតែកម្មត្រូវទឹងព្រាត់    អំពើបងធ្វើឲ្យសោហ្មង
ឲ្យប្អូនឃ្លាតចាកចេញពីបង    ស្នេហ៍ស្នងម្ទះសម្អកឃ្លានបាយ ។
លង់លុះព្រលប់យប់ស្ងាត់ឈឹង    កុមារខំប្រឹងរកខ្វល់ខ្វាយ
ពុតែស្ទូរមាត់សត្វទាំងឡាយ    បៀរព្រាយបួលជ្រករកទ្រនំ ។
ទើបចុះពីលើខ្នងអស្សពាហ៍    បួលទៅនិទ្រាក្រោមឈើធំ

កូនជនព្រឹក្សព្រៃស្វាត់ក្រៃធំ ដោយចិត្តក្រៀមក្រំអាណិតប្អូន ៗ
ម្ដេះដេកកូនព្រៃតែម្នាក់ឯង ចម្បែងទឹកបងឈឺងស្វាត់សូន្យ
មិនដែលធ្លាប់បែកពីបងប្អូន ម្ដេះសូនស្ងប់ស្ងាត់បាត់ស្មារតី ៗ
រឿងបងឈប់ស្ដេះប៉ុណ្ណេះសិន ខ្ញុំសូមថ្លាថ្លែងតាមសេចក្ដី
ពីអនុជប្អូននោះវិញនៃ ដេកនៅកូនព្រៃស្វាត់សូន្យឈឹង ៗ
លុះដល់ព្រឹកព្រានព្រះសុរិយា ភ្លឺច្បាស់ហើយណាកុមារប្រឹង
ត្រាច់ចរយាត្រាគិតរំពឹង កូនព្រៃស្រោងស្រឹងឥតមានស្រាក ៗ
ត្រាច់ទៅត្រាច់មករកពុំឃើញ កូនព្រៃញាតស្កាត់រតែលំបាក
ដើរតែម្នាក់ឯងវង្វេងគោកយ៉ាក បានផុតចេញចាកពីព្រៃធំ ៗ
បានចូលទៅដល់បុរនគរ សេមាបវររដ្ឋចេក្កចំក្រ
ផុតពីស្រុកតូចចូលស្រុកធំ ចេញពីនិគមដល់ជនបទ ៗ
លុះបានទៅដល់ផ្ទះយាយចាស់ តាចាស់ទាំងពីរពិតប្រាកដ
ដែលគាត់នៅកូនស្រុកជនបទ កំណត់នាយចក្រខុទ្យានធន ៗ
ដល់ហើយលើកដៃឡើងសំពះ យាយតារួចស្រេចឥតមានហ្មង
ខ្ញុំសូមនៅនឹងលោកយាយផង ដោយខ្ញុំទ័លក្រលំបាក ៗ
យាយតាទាំងពីរអេរសាទរ មិនគិតពីក្ដីក្រគោកយ៉ាក
មិនគិតអត់ឃ្លានប្រឹងចាកក៏ក ដោយពាក្យចចរថាចៅអើយ ៗ
ចូរចៅឡើងមកនៅនឹងយាយ សព្វថ្ងៃគ្មានចៅនឹងគេឡើយ

បានពីរនាក់តាចៅឯងហើយ ចៅអើយកុំឲ្យយាយស្ងាត់ពេក ៗ
កុមារនៅនឹងយាយតានោះ លង់លុះឆ្នាំបីជាលង្វែក
ឥតមានទុក្ខភ័យអ្វីបំឡែក មកបៀតបៀនកាយសប្បាយសុខ ៗ
ថ្លែងពីក្រុងសាកេតបុរី ក្សត្រថ្លៃសោយរាជ្យជាប្រមុខ
មហេសីបុត្រឥតមានទុក្ខ គ្មានហេតុកលិយុគដល់នគរ ៗ
ទ្រង់នាមព្រះបាទសាមលរាជ ព្រះអគ្គមហេសីស្រីសុន្ទរ
នាមរាជបុត្រីស្រីបវរ មូលីសុន្ទររាជក្សត្រិយ៍ ៗ
ឆោមឆាយកាយឆើតកើតក្នុងភព ល្អសព្វគ្មានទាស់ទំនាស់អ្វី
មានគ្រប់បញ្ចពិធកល្យាណី ស្រីគ្រប់លក្ខណ៍សក្តិសមប្រាណ ៗ
ល្អទាំងឫកពាទាំងដំណើរ ល្អល្អះប្រសើរឥតប្រៀបបាន
ទ្រង់ព្រះយាងយាត្រក្នុងរាជស្ថាន អត់ទ្រាំពុំបានមើលភ្លេចខ្លួន ៗ
ឃើញវរក្សត្រិយ៍ស្រីទ្រង់ភ័ក្ត្រ ល្អឯកឥតអាក់សក្តិសមសួន
អ្នកណាឃើញហើយសឹងភ្លេចខ្លួន ជាប់ជួនសួនចិត្តឥតមានស្រាក ៗ
មានកាលសម័យថ្ងៃមួយណា ចៅនឹងជីតានាំគ្នាចាក
ចេញពីផ្ទះទៅគ្មានសំរាក ថែទាំសួនច្បារឥតច្រានហោង ៗ
ថ្លែងពីមូលីសុន្ទរស្រី អផ្សុកព្រះទ័យពេកកន្លង
ចង់ទតសួនច្បារលេងបានមួង គិតស្រេចហើយហោងចរយាត្រា ៗ
ឡើងលើប្រាសាទប្រសើរខ្ពស់ លុតជង្គង់ចុះលើកហត្ថា

សូមទ្រង់បពិត្រព្រះបិតា　　នឹងព្រះមាតាទាំងពីរពង្ស ៗ
កូនសូមក្រសាលលេងឧទ្យាន　　កំសាន្តអផ្សុកទុក្ខក្នុងអង្គ
លេងក្នុងសួនច្បារអស់ចំណង់　　ចុះស្រង់ក្នុងស្រះលេងសប្បាយ ៗ
ទើបស្ដេចត្រាស់ហៅពួកសេណីយ ឲ្យរៀបស្នំស្រីធាប់ខ្វល់ខ្វាយ
ដង្ហែបុត្រីស្រីគបកាយ　　កំសាន្តសប្បាយក្នុងសួនច្បារ ៗ
អមាត្យរៀបស្រេចក្រាបពិត្រទូល　　បពិត្រឥសូរស្រេចហើយណា
សូមយាងព្រះនាងចេញយាត្រា　　គង់លើវណាមាសប្រសើរ ៗ
ឡើងស្រេចព្រះនាងយាងចេញវៃ　　ផុតពីកំពង់ជ័យស្រីស្នំដើរ
ដង្ហែមុខក្រោយដោយអើពើ　　អមាត្យត្រួតមើលមុខក្រោយផង ៗ
ព្រះនាងយាងដល់ទីសួនច្បារ　　ឃើញអង្គកុមារល្អកន្ទង
ថែរទាំសួនច្បារស្អាតមង្ហង　　ល្អជាងសព្វដងគួរចង់មើល ៗ
ឃើញតានឹងចៅទៅជិតគ្នា　　ទេវីលេលាយាងដដើល
ត្រេបបរបួលជិតទស្សនាមើល　　ចង់ព្រើលព្រឺព្រួចគួបក្នុងចិត្ត ៗ
នាងមានសវនីយ៍ត្រាស់ទៅថា　　នៃព្រះកុមារល្អពេកពិត
សួនច្បារនេះណាដូចនិមិត្ត　　គួរឲ្យមានចិត្តរីករាយក្រៃ ៗ
ដូចជាទេវតាមកតែងទុក　　មិនមែនទំនុកមនុស្សវិស័យ
ទេវតាតាំងទុកនៅក្នុងព្រៃ　　គួរឲ្យសម័យជាប់ចិត្តពេក ៗ
ឯពួកស្រីស្នំក្រុមសេនា　　យោធាច្រើនក្រៃជាអនេក

លេងក្នុងសួនច្បារសប្បាយថ្ងៃក ដើរមែកបេះផ្កាលេងសប្បាយ ៗ
ខ្លះនាំគ្នាលេងពួនក្នុងព្រៃ ទាំងប្រុសទាំងស្រីលបលាក់កាយ
ក្រោមក្នុងគុម្ពផ្កាចិត្តរីករាយ ប្រុសពាល់ត្រូវកាយសម្ងំនៅ ៗ
ដោយមានតណ្ហាស្រើបស្រាលខ្លាំង វង្វេងក័ន្ទកាំងក្មេងខុសត្រូវ
សប្បាយអស្ចារ្យក្នុងព្រៃជ្រៅ ក្មេងនាងស្រីពៅទាំងអស់គ្នា ៗ
ថ្លែងពីក្សត្រិយ៍ស្រីវរលក្ខណ៍ នាងមានចិត្តស្ម័គ្រនឹងកុមារ
ព្រះទ័យជាប់ចិត្តស្និទ្ធស្នេហា ជាទៃលោកតានៅនេះបុះ ៗ
ខ្ញុំនាំកុមារលេងសប្បាយ ឲ្យបានស្រួលកាយកុមារនោះ
ចូលក្នុងសួនច្បារផ្កាវាយរុះ ខ្លះរីកស្គុលស្គុះជ្រុះព្រោងព្រាយ ៗ
ឯអង្គកុមារពុំដឹងខ្លួន ជានាងស្រីនួនប្រាថ្នាកាយ
នាំនាងទតផ្កាលេងសប្បាយ ពុំដឹងក្នុងកាយដល់តិចឡើយ ៗ
នាងនាំចូលក្នុងសួនច្បារស្ងាត់ ថ្ពល់ពាត់ខ្លែងខ្លាតចិត្តឥតស្បើយ
នាំអង្គកុមារលេងលំហើយ ស្រេចហើយចូលស្រង់ក្នុងស្រះស្រី
ឲ្យអង្គកុមារចូលស្រង់ផង មុជលេងលងល្បែងមេត្រី
នាងបាចសពៅកុមារខ្ចី មុជដេញស្រីថ្លៃនាងហែលទៅ ៗ
បាចសកុមារពីទឹករាក់ ដេញផ្ទាក់រហូតដល់ទឹកជ្រៅ
កុមារខំហាចហែលចូលទៅ ស្រីពៅប្រវាឱបកុមារ ៗ
ដោយសម្ពស្សស្រីក្ដីសំរេច កុមារស្រៀវស្រើបក្នុងកាយា

នៅក្នុងស្រះស្រីរ៉ាវថ្វា គ្មានអ្នកឯណាជាពីរផង ៗ
រាគៈតណ្ហាបណ្ដាលឡើង ដោយក្ដីស្នេហាពេកកន្ទួង
ឡើងចាកពីស្រះស្រេចជាម្ដង ផ្លាស់ព័ស្ដុហើយហោងយានចូលព្រៃ ៗ
ពីរនាក់នឹងអង្គវរកុមារ ដោយក្ដីស្នេហានាងស្រីថ្លៃ
ប្រកៀកប្រកិតកាយក្នុងព្រៃ ក្សត្រីយ៍នាងធ្វើជាអៀនអន់ ៗ
ចេញចាកពីព្រៃស្រីធីតា នឹងអង្គកុមារនេត្រាគន់
សំដៅកន្លែងតាពីមុន ក្សត្រិយ៍តូបតន់ចាំពួកពល ៗ
លុះយូរបន្តិចពួកស្នំស្រី ត្រឡប់វិលវៃទាំងរេហ៍ពល
ចរចូលមកជិតបង្គំគាល់ ក្សត្រិយ៍និមលគ្មានអន់អាក់ ៗ
ព្រះនាងមានព្រះវាចា នឹងពួកស្រីគ្នាដោយស្មោះស្ម័គ្រ
លេងក្នុងសួនបុប្ផាផ្កាក្រងផ្ទាក់ កម្រងមួយម្នាក់ពាក់គ្រប់ដៃ ៗ
សប្បាយណាស់បងទាំងអស់គ្នា ពេលខ្ញុំកំព្រានៅក្នុងព្រៃ
បានអង្គកុមារនឹងតាថ្លៃ កុំអីខ្ញុំតាមបងទៅហើយ ៗ
ខ្ញុំនឹកអាណិតបងគ្រប់គ្នា មិនធ្លាប់លេលាសប្បាយឡើយ
យើងលេងស្រះទៀតឃ្លាតជាត្រើយ ងូតទឹករួចហើយសឹមយាត្រា ៗ
ជម្រះមន្ទិលក្អួលសៅហ្មង ដែលកើតមានផងពីពៀសណា
យើងប្រឹងត្រាប់លេងក្នុងព្រឹក្សា ស្រង់រ៉ាវថ្វាស្អាតប្រសើរ ៗ
ទេវីនាំអស់ស្នំបរិពារ ចុះស្រង់គង្គាហែលលុលលើ

នាំតាំងកុមារប្រុសប្រសើរ លលើហៃលលេងសប្បាយចិត្ត ៗ
ដោយក្ដីស្នេហានាងទេវី នារីឲ្យអង្គកុមារស្និទ្ធ
ហិចហៃលសសៀរចូលមកជិត វរមិត្រជិតដេញកុមារា ៗ
ឯពួកគីលៀងរៀងរាល់ប្រាណ មុជលេងកំសាន្តសព្វកាយា
នូវពួកសេណីយនឹងសេនា សប្បាយត្រេកត្រអាលកំរើកខ្លួន ៗ
ខ្លះបែបង់គ្នាលេងកងទឹក ផ្អើលហ្វឹកបែបជាមោលពោពួន
ខ្លះហៃលទៅជ្រែកលបលាក់ខ្លួន បំពួនទឹងស្ទឹកកំពង់ពួយ ៗ
ខ្លះមុជទៅឲបក្រសោបប្រាណ ចាប់បានរហូតដល់កាយសួន
គីលៀងសប្បាយរៀងរាល់ខ្លួន សមសួនដោយចិត្តស្និទ្ធមេត្រី ៗ
ខ្លះត្រេកត្រអាលទៅនឹងប្រុស មុជជ្រែកនឹងគុម្ពចង្កលណី
បន្ទាប់គកក្បាលហើយទះដៃ ប្រុសមុជចៀវចែសំដៅទៅ ៗ
ក្រសារក្រសោបឲបប្រកិត កៀកកាយជួលជិតនិត្យនឹងនៅ
ដោយត្រេកត្រអាលកងទឹកជ្រៅ បំបែរបៀតទៅគុម្ពត្រគៀត ៗ
ខ្លះស្នេហាពេកឲបពុំបាន យកដៃទៅច្រានត្រង់កន្ទៀត
ញញឹមពារទៅជិតគុម្ពត្រគៀត ផ្ទាស់ផ្ទៀតប្រលោមលោមស្រីៗ ៗ
ត្រគៀតដូចបង្រែកកង់សួន ត្រកួនដូចបង្រែកងបី
ព្រលិតដូចបង្រែលែងស្រី ចង្កលណីដូចបង់ចង្កល្យាណ ៗ
ឯពួកសេនានឹងសេណី នឹងអស់ស្ត្រីស្រែតាំងប៉ុន្មាន

នាំវរក្សត្រិយ៍ស្រង់កំសាន្ត　ស្រេចបានឡើងចាកស្រះគង្គា ៗ
ទើបផ្លាស់ព្រះពស្ត្ររៀងរាល់ប្រាណ　ក្សត្រិយ៍កល្យាណលាកុមារ
លាទាំងលោកតានាយសួនប្ការ　ចេញផុតហើយណាចូលវាំងវៃ ៗ
ដល់ថ្វាយបង្គំក្សត្រទ្វេហា　បពិត្របិតាមាតាថ្លៃ
កូនសុំលាចេញទៅលេងព្រៃ　សប្បាយពេកក្រៃឥតឧបមា ៗ
សូមទានឥតទោសសន្តោសខ្ញុំ　មេត្តាសូមសុំព្រះករុណា
ទាំងពីរមាតានឹងបិតា　សូមអត់ទោសាខ្ញុំនៅក្មេង ៗ
ក្សត្រាទាំងពីរទ្រង់ត្រាស់ថា　ព្រះទ័យករុណាគិតយល់ឈ្វេង
អាសូរកូនពេកពៅនៅក្មេង　ចេះបរបាចែងថ្លៃសំដី ៗ
ណ្ហើយចុះកូនអើយយើងអត់ទោស　យើងអត់អំណត់ចិត្តខន្តី
ទោះទោសតូចធំប៉ុន្មានក្តី　កូនស្រីៗពុកអត់ទោសឲ្យ ៗ
រឿងនេះយើងស្វែះប៉ុណ្ណោះសិន　មិនទាន់បរបាទុកខាងក្រោយ
ថ្ងៃពីកុមារនឹងតាហើយ　បណ្តីររដយទៅឯផ្ទះ ៗ
ចំណែកខាងយាយចាំមើលផ្លូវ　តាហើយនឹងចៅបាត់យូរណាស់
រវល់ធ្វើអ្វីមិនមកផ្ទះ　គិតណាស់តែចៅក្រែងឃ្លានបាយ ៗ
គំនិតយាយគិតតែប៉ុណ្ណោះ　ក្រឡេកឃើញតាពីចម្ងាយ
មាត់សើចក្អាកៗដៃដួសបាយ　ថានែចៅអើយញាំបាយទៅ ៗ
រឿងចៅនឹងយាយហើយនឹងតា　យើងឈប់បរបាបង្អង់នៅ

ថ្លែងពីក្សត្រាព្រះបមខៅ ដែលស្តេចគង់នៅក្នុងសេមា ។
ស្តេចទ្រង់ប្រឈួនជាទម្ងន់ អាពាធឈឺធ្ងន់ពេកណាស់ណា
ទើបស្តេចទ្រង់ថ្លែងព្រះឧង្ការ ត្រាស់ហៅសេនាទឹងសេណី ។
ត្រាស់ហៅអមាត្យពួកធំៗ មូលមកប្រជុំនឹងក្នុងវ្យ៍
ហៅទាំងសុន្ទរអគ្គមហាសី ហៅទាំងបុត្រីស្រីជីតា ។
មូលមកប្រជុំស្រេចជាម្តង ក្សត្រាប្រកាស់ច្បងថ្លែងឧង្ការ
មន្ត្រីតូចធំទាំងអស់គ្នា ជួយថែរក្សាព្រះនគរ ។
ខ្ញុំឈឺម្តងនេះគ្មានសង្ឃឹម ទៅនែមហាសីស្រីសុន្ទរ
ថែកូនប្អូនថែទាំងនគរ ស្រីស្រស់បវរមកជិតបង ។
បងព្រាត់ចោលប្អូនថ្ងៃនឹងហើយ សុន្ទរបងសូមអផ្អែលខ្នង
ថែកូនឲ្យល្អណាមាសបង ថែមន្ទីផងឲ្យបានសុខ ។
នាងរក្សាចិត្តឲ្យបានល្អ ប្ដូរនាងយកធម៌មកតាំងទុក
ការល្អកុំធ្វើឲ្យអាក្រក់ ប្ដូររក្សាទុកណាប្អូនស្រី ។
ទ្រង់មានបន្ទូលតែប៉ុណ្ណោះ ខ្យល់ដកហូតចុះអស់វិថី
សង្ខាររលត់ពេចខ្ចី វិថីរលត់ព្រមទាំងអស់ ។
នៅតែមនោវិថីមួយ នាំសួយអណ្ដាតត្រៃសែតខ្ពស់
បង្កើតក្នុងស្ថានសួគ៌ឯណោះ ប្រាសាទខ្ពង់ខ្ពស់ប្រសើរក្រៃ ។
មហាសីបុត្រីទាំងពីរអង្គ សោយសោកខ្សឹកខ្សួលដោយអាល័យ

សោកទាំងនាម៉ឺនមុខមន្ត្រី សេនាបតីកុង្ស្រីយ៍ផង ។
ទើបលើកព្រះសពដាក់កោដិមាស បម្លាក់ពេញពាសល្អក្នុង
បូជាព្រះសពស្រេចជាម្ដង គ្រប់គ្រងនគរសុន្ធរស្រី ។
ក្សត្រិយ៍ប្រជុំពួកនាម៉ឺន គិតផ្សេងរកអ្នកមានបារមី
បុស្សរថប្រសើរលើសហត្ថី សម្បុរសខ្ចីក្ដុកខៀវផង ។
មន្ត្រីទាំងអស់យល់ព្រមព្រៀង ទុក្ការព្រះនាងបន្ទូលផ្សង
ដល់ពួកទេវតាឥន្ទ្រព្រហ្មផង សូមដូចបំណងប៉ងប្រាថ្នា ។
បើអ្នកមានបុណ្យមានអំណាច ត្រូវទឹងសោយរាជ្យព្រះសេមា
សាកេតបុរីនេះឯងណា ឲ្យឃើញអស្ចារ្យទឹងដំរី ។
ទើបយកប្រដាប់សំរាប់រាជ្យ សំរាប់ឡើងគង់ព្រះវែទនថ្មី
លើកដាក់ទៅលើខ្នងហត្ថី ដំរីបុស្សរថប្រសើរក្រៃ ។
ដំរីចេញផុតពីនគរ សំដៅជនបទផ្ទះយាយតា
ដែលគាត់តែងធ្វើនាយសួនច្បារ តែងថែរក្សាចៅមួយផង ។
ដំរីទៅដល់ថ្វាយបង្គំ បរមកុមារស្រេចជាម្ដង
ពួកពលឃើញហើយសរកន្ទង ថ្វាយបង្គំផងទាំងអស់គ្នា ។
ទើបយកប្រដាប់សំរាប់រាជ្យ ទ្រង់ផ្លាស់ព្រះពស្ដ្រាជកុមារ
ទើបយាងលើខ្នងគជេន្ទ្រ បុស្សរថថ្លៃថ្លាប្រសើរក្ដាត់ ។
ឲ្យតាយកខ្សែចងឯងផង យាយយកដំបងវាយឯងថ្វាត់

ខ្ញុំយកទៅទុកកុំឲ្យបាត់ ប្រយ័ត្នក្រែងខានការពារខ្លួន ៗ
តាយាយខ្ញុំលាទៅសិនហើយ តាអើយថែយាយឲ្យមាំមួន
បើយាយនៅផ្ទះតាទៅសួន កុំប្រហែសខ្លួនយាយចាស់ហើយ ៗ
កុមារលាស្រេចបវរិលវៃ ចូលក្នុងវាំងជ័យសោមាហើយ
ឯពួកមន្ត្រីហែមុខក្រោយ អរហើយសែនអរឥតឧបមា ៗ
នាម៉ឺនតូចធំមូលប្រជុំ ក្សត្រិយ៍ឧត្តមសុន្ទរណា
ឲ្យហៅបុត្រស្រីកញ្ញា មូលីធីតាសុន្ទរផង ៗ
យើងគិតរៀបចំតាំងអភិសេក មូលីសុន្ទរធីតាហោង
ទីងព្រះអនុជាសោយរាជ្យគ្រង ដំណាងមាតាបិតាវិញ ៗ
តើអ្នកទាំងឡាយថាដូចម្តេច ហ៊ឹនមុខមន្ត្រីអ្នកប្រាប់អញ
ទោះបីស្រឡាញ់មិនស្រឡាញ់ អ្នកប្រាប់ឲ្យអញខ្ញុំដឹងផង ៗ
មន្ត្រីតូចធំលើកអញ្ជលី ទូលព្រះទេវីដោយទំនង
ក្សត្រថ្វៃទាំងពីរល្អឥតហ្មង ល្មមលើកឲ្យគ្រងរាជ្យសោមា ៗ
នាម៉ឺនប្រជុំជំនុំស្រេច ព្រមទាំងសម្តេចព្រះមាតា
ឲ្យព្រះរាជបុត្រទាំងពីរណា គ្រងព្រះភាពរាជបុរី ៗ
រឿងនេះខ្ញុំស្ទុះដោយសង្ខេប ពោលតាមបទបែបវែងពេកក្រៃ
សូមពោលដំណាតសេចក្តី ពីព្រះរៀមថ្លៃចៅពលឯក ៗ
ជិះសេះរកប្អូនក្នុងព្រៃក្បា ពុំឃើញឡើយណាស្រក់ទឹកភ្នែក

ទាំងយប់ទាំងថ្ងៃពុំបានដេក នឿយហត់ខ្លាំងពេកស្គមអស់ខ្លួន ៗ
លុះដើរទៅដល់បុរីនគរ សោមាបវររដ្ឋប្រសើរ
ស្តេចមានបុណ្យខ្លាំងអំណាចលើ លើសលប់ប្រសើរជាងស្តេចផង ៗ
ទ្រង់ព្រះនាមថាស្តេចព្រហ្មទត្ត សោយរាជសម្បត្តិសម្បូណ៌ហោង
ក្រុងពារណាសីធំកន្លង ក្សត្រថ្លៃច្បាស់ច្បងមានមហេសី ៗ
ឯវរជាយាជាឯកអគ្គ ព្រះនាមវររត្នរាជក្សត្រីយ៍
សុវណ្ណអម្ពរភ័ក្ត្រប្រិមប្រិយ៍ ប្រសើរលើសស្រីស្នំទាំងឡាយ ៗ
ស្តេចមានព្រះរាជបុត្រី ស្រស់ស្រីរូបកើតឆើតឆោមឆាយ
ប្រសើរលើសលប់ស្រីទាំងឡាយ រូបកាយប្រសើរស្មើស្រីសួគ៌ ៗ
ព្រះនាមសុវណ្ណអម្ពរស្រី ភ័ក្ត្រស្រស់ប្រិមប្រិយ៍ដូចគំនូរ
ស្មើកិន្នរីបុត្រីឥស្សូរ ល្អគ្មានប្រៀបផ្គូកងលោកិយ ៗ
សោយរាជសម្បត្តិសុខសាន្តមក មិនដែលមានហេតុគ្រោះថ្នាក់អ្វី
ស្រាប់តែពេលនេះព្រះបក្រី ស្តេចទ្រង់អាពាធប្រឈួនធ្ងន់ ៗ
ទ្រង់ហៅមហេសីបុត្រីមក ប្អូនអើយលែលកស្រស់ស្រីគន់
អាពាធបងឈឺកាន់តែធ្ងន់ តួបគន់ថែទាំព្រះនគរ ៗ
ស្រាប់តែចាក់ដោតក្នុងទ្រូងបង នួនល្អងដូចជាកាំបិតគោរ
កាត់ក្នុងពោះវៀនធ្លាក់ចុះមក ប្អូនអើយមើលឈាមក្រហមច្រាល ៗ
ហេតុតែកម្មបងពីបុព្វេ វេរក្រងបងធ្វើគេពីក្នុងកាល

មុនធ្លាក់ឈាមមកក្រហមព្រាល នេះគឺកម្មកាលតាមទាន់ហើយ ៗ
ប្អូនអើយស្រីកុំសោយសោកបង នួនល្អងនាងកុំព្រើកន្តើយ
រក្សាទន្តរឲ្យល្អហើយ រក្សាកូនស្រីឲ្យបានសុខ ៗ
បូរប្អូនរក្សាមុខមន្ត្រី តូចក្តីធំក្តីតាមដោយមុខ
នាងប្រឹងថែទាំឲ្យបានសុខ ដំណើរទៅមុខនាងបានស្រួល ៗ
ទ្រង់មានបន្ទូលផ្តាំរួចស្រេច កម្មចូលមកផ្តាច់ដង្ហក់យោល
ពួកខ្យល់ទាំងអស់ប្រមូលមូល ទទួលវង្គតពេលនោះឯង ៗ
នាងទ្រង់តាំងរៀបពិធីបុណ្យ ប្រសើរវិសេសជាងជាក់ស្តែង
ធ្វើមេរុមណ្ឌបគ្រប់កន្លែង ភ្លឺផ្លុកបំពែងចិញ្ចាចក្រែ ៗ
ពិធីបុណ្យនេះច្រើនយ៉ាងណាស់ ខ្ញុំពោលកាត់ខ្លះកុំថាអ្វី
កុំឲ្យវែងពេកយូរពំរ៉ៃ អ្នកអានសេចក្តីនាំធុញទ្រាន់ ៗ
ប្រៀបដូចស៊ីស្ករផ្អែមច្រើនពេក នាំឲ្យក្តៅស្រេករអាល្ហាន់
សេចក្តីវែងពេកនាំធុញទ្រាន់ តែល្ហាន់លែងចង់ស៊ីទៀតហើយ ៗ
សង្ខេបញយ ៗ មិនចេះចប់ សូមថែងកំណត់បទខាងក្រោយ
ពីទៅពលឯកបែកប្អូនហើយ គ្រាក្រោយបានចូលដល់នគរ ៗ
ពាកណាសីនេះឯងណា ខំប្រឹងយាត្រាមិនឈប់ឈរ
លុះដល់ទៀបទីព្រះនគរ កុមារបវរបញ្ឈប់សេះ ៗ
នៅលើសាលាសំណាក់មួយ កុមារតែងព្រួយគិតត្រិះរិះ

អញគិតដេកលើសាលានេះ    លែងសេះឲ្យស៊ីស្មៅប្រញាប់    ៗ
ថ្ងៃពីទេវីរាជក្សត្រិយ៍    ធ្វើបុណ្យស្វាមីរួចស្រេចស្រាប់
ទ្រង់មានបន្ទូលត្រាស់បង្គាប់    ឲ្យប្រាប់សេនាមាត្យមន្ត្រី    ៗ
ថាទៃនាហ្មឺនគ្រប់អង្គា    ចូលនាំគ្នាជំនុំស្តី
យើងគិតរកស្តេចគ្រងបុរី    អ្នកមានបារមីបុណ្យប្រសើរ    ៗ
ទើបនាំឲ្យនាំដំរីមក    បុស្សរថពន្ទកល្អលប់លើស
ក្តុកទ្រៀវអន្ទង់ស្រស់ប្រសើរ    មកដល់នាងធ្វើសព្វាផ្សង    ៗ
ទាំងព្រាហ្មណ៍បារគូបុរោហិត    លើកដៃអធិដ្ឋានជាមុន
យើងខ្ញុំទាំងឡាយសូមបួងសួង    ទេវតាព្រហ្មផងនឹងព្រះឥន្ទ្រ    ៗ
លោកមានភ្នែកទិព្វត្រចៀកទិព្វ    ដែលទ្រង់ព្រះនាមជាទេវិន្ទ្រ
សោយរាជ្យនៅក្នុងស្ថានព្រះឥន្ទ្រ    ទ្រង់ជាអមរិន្ទ្រសហស្សនេយ៍    ៗ
សូមចុះមកជួយជាសាក្សី    ខ្ញុំផ្សងដំរីបុស្សរថថ្ងៃ
អ្នកណាមានបុណ្យបារមីក្រៃ    សូមឲ្យដំរីថ្វាយបង្គំ    ៗ
ផ្សងស្រេចនាងឲ្យលែងដំរី    យាត្រាចេញខ្មីសំដៅចំ
ដល់ព្រះកុមារថ្វាយបង្គំ    កំពុងតែផ្ទំលើសាលា    ៗ
កុមារឡើងគង់លើដំរី    ចាកសាលាខ្មីចូលសេមា
ឯអគ្គសម្តេចព្រះមាតា    អញ្ជើញកុមារឡើងប្រាសាទ    ៗ
ប្រជុំនាហ្មឺនមុខមន្ត្រី    ព្រមទាំងសេនីសេនាមាត្យ

នាងមានសវនិយ៍តទៅទៀត　　ជាវនអមាត្យផងគ្រប់គ្នា ៗ
ដ្បិតអ័អគ្គព្រះកុមារនេះ　　មានបុណ្យបារមីជាអស្ចារ្យ
យើងគិតអភិសេកឯកពជា　　គ្រប់គ្រងភាពបុរវដ្ឋ ៗ
ទឹងវក្សត្រិយ៍ស្រីសុវណ្ណ　　អម្ពរសាក័ណជាក់ប្រាកដ
ជាមហេសីធំកងរាជវដ្ត　　ប្រគល់សម្បត្តិពាភណសី ៗ
មន្ត្រីទាំងឡាយជាដូចម្ដេច　　ចូរអ្នកសម្រេចតាមសេចក្ដី
គំនិតរបស់ខ្ញុំជាស្រី　　វក្រែងស្ដីអាស្រូវត្រូវជួយគិត ៗ
បពិត្រក្សត្រិយ៍ថ្លៃប្រសើរ　　ដំណើរវផលទ្រង់ព្រះរះគិត
ជម្រិះបែបនេះឃើញត្រូវពិត　　តាមដោយសុចរិតបវេណី ៗ
ទើបនាងប្រគល់រាជសម្បត្តិ　　ក្រោមស្វេត្តច័ត្រលើមន្ទីរ
ឲ្យពរជល់បុត្រភជទាំងទ្វី　　ស្រោចទឹកកន្ទីក្រអូបសាយ ៗ
ទើបព្រាហ្មណ៍បារគូបុរោហិត　　លើកយកពាក្យពិតមកទំនាយ
សូមឲ្យក្សត្រាពីរព្រះកាយ　　សោយសុខសប្បាយព្រះជន្មវែង ៗ
ប្រទេសនានាសឹងគោតខ្លាច　　សូមឲ្យអំណាចខ្ពស់ចំពែង
សត្រូវជិតឆ្ងាយពីស្ដាំឆ្វេង　　សូមអស់រលីងរលត់ហោង ៗ
ព្រាហ្មណ៍ថ្វាយពរស្រេចកាលណា ហើយ ទាំងពីរក្រសត្រិយ៍យាងចុះផ្គង
បាកស្វេត្រច័ត្រស្រេចជាមួន　　ស្ដេចឡើងគង់លើប្រាសាទជ័យ ៗ
ចូលផុំវនចន្ទិត្យនឹងសុវណ្ណ　　អម្ពរសាក័ណក័ក្រប្រិមប្រិយ

ដែលទើបគិតសោកបានថ្កានថ្កី　បក្រិជុំអែបនៃបនារី ៗ
ដោយពេញព្រះទ័យនឹងរូបឆោម　ស្ដេចទ្រង់ប្រលោមនាងទេវី
ព្រះទ័យស្នោះស្ម័គ្រនឹងទេពី　ឥតមាននារីណាផ្ទឹមបាន ៗ
រីឯព្រះបាទឯកអគ្គច្កើង　តាំងឡើងសោយរាជ្យបានចុំថ្កាន
ល្បីឮរន្ធឺទៅសព្វស្ថាន　ស្ដេចមានសម្បត្តិពីរប្រការ ៗ
មានកន្សែងបក់កន្សែងបោយ　ស្ដេចមានតាំងត្មាំងធ្មិនឯងណា
ឮល្បីសម្បត្តិពីរប្រការ　ដល់ស្ដេចណាៗសឹងកោតខ្លាច ៗ
ឯស្ដេចដទៃនាំសួយមក　ថ្វាយក្សត្រពន្ធកព្រោះអំណាច
គ្រាន់តែឮឈ្មោះសឹងខ្ចបខ្លាច　ព្រោះព្រះអំណាចបញ្ច័រផែនដី ៗ
នៅតែព្រះបាទអនុជា　សោយរាជ្យនៅសាកេតបុរី
មិនខ្លាចអំណាចពាកណសី　ដោយអាងបារមីបុទ្ធិចេស្ដា ៗ
ដោយស្ដេចមានខ្សែចងឯងផង　មានតាំងដំបងវាយឯងណា
ល្បីល្បាញលើសលប់កពលោកា　គ្មានស្ដេចឯណាហ៊ានប្រមាថ ៗ
ឫទ្ធិឮដល់ពាកណសី　ឯកាចក្រីក្សត្រីយ៍នរនាថ
មិនឃើញសួយសាករថ្វាយទៀត　តាមជាតិសាកេតកជបុរី ៗ
ទម្លាប់ធ្លាប់តែនាំថ្វាយ　មកថ្វាយដល់ក្រុងពាកណសី
ឥឡូវបាត់សោះព្រោះហេតុអ្វី　សាកេតបុរីមិនឃើញមក ៗ
ទើបត្រាស់ឲ្យហៅរាជទូតទ្វី　អាឡាក់ពីរបីទ្រង់ឲ្យយក

ក្រដាសទឹកខ្មៅសរសេរភ្លាក     ទើបយកមកជូនថ្វាយក្សត្រា ៗ
យើងជាព្រះចៅពាកណសី     រាជទូតនាំខ្ញីព្រះរាជសារ
ចុតហ្មាយឡាយព្រះហស្តលេខា     ឲ្យស្តេចក្រុងសាកេតបុរី ៗ
នាំអស់សួយសាអាករមក     ថ្វាយយើងឲ្យឆាប់ប្រញាប់ខ្ញី
ក្នុងពេលឥឡូវនេះឯងនែ     ដល់ពាកណសីនគរយើង ៗ
បើធ្វើតាមរាជតម្រាស់នេះ     សាកេតបុរីនឹងបានចម្រើន
បើស្តេចមិនធ្វើតាមសារយើង     សាកេតបុរីវិនាសហើយ ៗ
បញ្ចប់រាជសារតែប៉ុណ្ណេះ     អ្នកស្តេចគិតត្រិះកុំកន្តើយ
មិនទ្រង់តាមព្រះបង្គាប់ឡើយ     នេះហើយទទឹងរាជឧក្ការ ៗ
ទូតយករាជសារដាក់ក្នុងស្រោម     ស្តេចទ្រង់ប្រថាប់ព្រះសង្ហារ
ឈ្មោះអ្នកដទៃមិនត្រូវការ     បើកព្រះសង្ហារត្រូវមានទោស ៗ
រាជទូតក្រាបថ្វាយបង្គំលា     ចេញក្រៅសេមាបុរីនោះ
សំដៅនគរដែលចំណុះ     នាមឈ្មោះសាកេតរាជបុរី ៗ
ដល់ហើយចូលក្រាបថ្វាយបង្គំ     លើកហត្ថប្រណម្យដាក់សិរសី
ទូលថាសារនេះព្រះចក្រី     ក្រុងពាកណសីនាំមកថ្វាយ ៗ
ទើបស្តេចទទួលរាជសារនោះ     ហូតចេញពីស្រោមឆាប់ខ្វល់ខ្វាយ
ទ្រង់ទតរាជសារដោយភេះភាយ     ស្តេចទ្រង់បានជ្រាបសព្វសេចក្តី ៗ
ទើបស្តេចឲ្យហៅអាឡក់មក     ឲ្យយករាជសារមួយឡើងខ្ញី

ថាយើងសាកេតរាជបុរី
បក្រីព្រះនាមអនុជា ។
សព្វថ្ងៃត្រង់បុទ្ធិនឹងអំណាច
យើងឥតមានខ្លាចស្តេចឯណា
បើពាកណាសីមានប្រាជ្ញា
ចង់បានសេមាសាកេតនេះ ។
ឲ្យបួលមកឆាប់ប្រញាប់ឡើង
ព្រះបាទថ្កុំថ្កើងកុំវេរិះ
យើងអនុជាពុំសូវបេះ
ជាម្រះអំពីខាងចម្បាំង ។
ស្តេចបួលមកបុះយើងឥតធុញ
ឥតរាឥតរុញនឹងប្រណាំង
ឯត្រង់ពីខាងរឿងចម្បាំង
យើងឥតក័ន្តកាំងខ្ទបខ្លាចឡើយ ។
រាជទូតនាំសារត្រឡប់វិញ
ដល់ពាកណាសីនគរហើយ
ថ្វាយសារដល់ក្សត្រាត្រាណត្រើយ
ស្តេចទតសព្វហើយជ្រប់កន្ត្រា ។
ក្តៅអើយសែនក្តៅក្នុងព្រះទ័យ
ដូចអគ្គិសនីឆេះខ្ទា៉
ទើបលើកព្រះហស្តទះតុថា
អាចោរមោហាព្រហើនក្រៃ ។
ខ្សែមួយនេះឯងបែងចប់ហើយ
ចម្បាំងខាងក្រោយខ្សែពីរនៃ
ចម្បាំងនោះធំណាស់ល្អស្តាប់ក្រៃ
ខ្សែមួយនេះនៃចប់ហើយហោង ។

ទីមួយ-ចប់

ពលឯកកុមារ-មាឥត

បម្យាំងទីពីរទៅទៀត

*សូមជាវបន្ត ព្រោះរឿងខាងចុងពីរោះណាស់*

រោងពុម្ពកុមារពាណិជ

លេខ ៦ មហាវិថីឡេងសីសុវត្ថិ ភ្នំពេញ